00657364

E9/15/1

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ:

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត: សាធារណៈ / Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹង "ញត្តិរបស់ អៀង សារី គាំទ្រសាក្សីមួយចំនួន ដែលស្នើឡើងដោយក្រុមមេធាវីការពារក្តីផ្សេងៗទៀត"**

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ អូត្ដារ៉ា

**ចម្លងជូន:**
ជនជាប់ចោទ:
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe

លោក អាង ឧត្តម

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception):
28 / 03 / 2011
ម៉ោង (Time/Heure) : 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

លោក Michael G.KARNAVAS
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC
លោក សរ សុវ៉ាន
លោក Jacques VERGÈS
លោក Phillipe GRECIANO

## ១. សេចក្ដីផ្ដើម

១. នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១១ អៀង សារី តាមរយៈមេធាវីការពារក្ដីរបស់ខ្លួន ("មេធាវីការពារក្ដី") បានដាក់ "ញត្តិគាំទ្រសាក្សីមួយចំនួនដែលស្នើឡើង ដោយក្រុមការពារក្ដីផ្សេងៗទៀត"[1] ("ញត្តិ") ។ មេធាវីការពារក្ដីអះអាងថា សាក្សីមួយចំនួនដែលស្នើឡើងដោយ នួន ជា និង ខៀវ សំផន នឹងជួយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងការកំណត់អំពីអង្គហេតុជាក់ស្ដែងនៅក្នុងបញ្ហានេះ និងស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង កោះហៅសាក្សីទាំងនេះនៅពេលសវនាការ[2] ។ អាស្រ័យដូចមូលហេតុខាងក្រោមនេះ សហព្រះរាជអាជ្ញាស្នើឲ្យបដិសេធចោលញត្តិនេះ ដោយសារថាមេធាវីការពារក្ដីខកខានមិនបានផ្ដល់មូលហេតុថា ហេតុអ្វីបានជាការយឺតយ៉ាវក្នុងការដាក់ញត្តិនេះគួរត្រូវបានទទួលយក ហើយពួកគាត់ខកខានមិនបានបង្ហាញថា វាស្ថិតក្នុងផលប្រយោជន៍នៃយុត្តិធម៌ក្នុងការកោះហៅសាក្សីដែលបានកំណត់អត្តសញ្ញាណទាំងនេះ ។

## ២. អង្គហេតុពាក់ព័ន្ធ

២. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះ បានចេញសេចក្ដីសម្រេចរបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍នានាប្រឆាំងនឹងដីកាដំណោះស្រាយ ហេតុដូច្នេះហើយបានធ្វើឲ្យដីកាដំណោះស្រាយចូលជាស្ថាពរ[3] ។ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញដីកាបង្គាប់ត្រៀមរៀបចំសវនាការរបស់ខ្លួនដែលតម្រូវឲ្យគ្រប់ភាគីទាំងអស់ដាក់ឯកសារ៖ (១) បញ្ជីឈ្មោះ

---

[1] ឯកសារលេខ E9/15, "ញត្តិរបស់ អៀង សារី គាំទ្រសាក្សីមួយចំនួនដែលស្នើឡើងដោយក្រុមការពារក្ដីផ្សេងៗទៀត", ១៦ មីនា ២០១១, ERN 00652121-23 ។

[2] ញត្តិ, កថាខ័ណ្ឌទី១-៣ ។

[3] ឯកសារលេខ D427/4/14, "សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ", ១៣ មករា ២០១១, ERN 00634903-06។ ឯកសារលេខ D427/2/12, "សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និងនួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ", ១៣ មករា ២០១១, ERN 00634916-22 ។ ឯកសារលេខ D427/1/26, "សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ", ១៣ មករា ២០១១, ERN 00634887-91 ។

សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលខ្លួនមានបំណងស្នើសុំអោយកោះហៅ ហើយដែលអ្នកទាំងនោះមិនបានស្នើសុំនូវវិធានការការពារ; (២)បញ្ជីឈ្មោះសាក្សី ឬ ដើមបណ្តឹងរដ្ឋប្បវេណីថ្មីដែលស្នើសុំវិធានការការពារ; (៣) ព័ត៌មានដែលតម្រូវអោយមាន ទាក់ទងទៅនឹង សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលស្នើឡើង; (៤) បញ្ជីនៃអង្គហេតុ ដែលមិន មានការតវ៉ា រួមទាំងអង្គហេតុដែលបានធ្វើការវិនិច្ឆ័យរួចហើយដោយអង្គជំនុំជម្រះក្នុងសំណុំរឿងលេខ ០០១ និង (៥) បញ្ជីនៃឯកសារ និងវត្ថុតាង[4]។ អង្គជំនុំជម្រះ បានកំណត់កាលបរិច្ឆេទចុងក្រោយសម្រាប់សហព្រះរាជអាជ្ញាដើម្បីដាក់បញ្ជីសាក្សី អ្នកជំនាញ និងភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលស្នើឡើងរបស់ខ្លួន មានរយៈពេល១៥ថ្ងៃ គិតចាប់គិតពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ ។ ភាគីដទៃទៀតត្រូវបានបង្គាប់ឱ្យដាក់បញ្ជីសាក្សី អ្នកជំនាញ និងភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលស្នើឡើងរបស់ពួកគេ ក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីសហព្រះរាជអាជ្ញា បានដាក់បញ្ជីនានារបស់ខ្លួន ។

៣. នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ សហព្រះរាជអាជ្ញា បានដាក់បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលស្នើឡើងរបស់ខ្លួន អនុលោមតាមវិធាន ៨០ ("បញ្ជីសាក្សីរបស់សហព្រះរាជអាជ្ញា")[5] ដែលបានជូនដំណឹងនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ ។ នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់គូភាគីថា ការពន្យារពេលដាក់បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងភាគីដើមបណ្តឹងរដ្ឋប្បវេណីដូចបានស្នើឡើងដោយ អៀង សារី នួន ជា និង អៀង ធីរិទ្ធ នឹងមិនត្រូវបានអនុញ្ញាតឡើយ[6] ។ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ មេធាវីការពារក្តីបានដាក់ "បញ្ជីស្នើឈ្មោះអ្នកជំនាញរបស់ អៀង សារី និងការជូនដំណឹងអំពីបញ្ជីសាក្សី និងភាគី

[4] ឯកសារលេខ E9, អង្គជំនុំជម្រះសាលាដំបូង "ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីត្រៀមរៀបចំសវនាការ", ១៧ មករា ២០១១ ។

[5] ឯកសារលេខ E9/4, "បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងភាគីដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញា រួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១, ទី២, ទី៣, ទី៣ក, ទី៤ និង ទី៥", ២៨ មករា ២០១១, ERN 00640669-76 ។

[6] ឯកសារលេខ E35, "ការជូនដំណឹងជាមុនអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ទាក់ទងនឹងឯកសារដែលមានលេខ E14, E15, E9/2, E9/3, E24 និង E27", ៣ កុម្ភៈ ២០១១ (បានជូនដំណឹងនៅថ្ងៃទី៨ កុម្ភៈ ២០១១), ERN 00642291 ។

00657368



ដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់" ("បញ្ជីអ្នកជំនាញរបស់មេធាវីការពារក្ដី")[7] ។ នៅទីនេះ មេធាវីការពារក្ដីបានជម្រាបអង្គជំនុំជម្រះ ថាខ្លួននឹងមិនដាក់បញ្ជីឈ្មោះសាក្សីក្នុងពេលនេះទេ។

"លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់("មេធាវីការពារក្ដី") សូមដាក់ជូនមកជាមួយនេះនូវបញ្ជីឈ្មោះអ្នកជំនាញ និងសូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង នៅខណៈនេះថា *លោកគ្មានបំណងក្នុងការកោះអញ្ជើញសាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណី។ ដូច្នេះហើយលោកមិនអាចផ្ដល់អោយអង្គជំនុំជម្រះសាលាដំបូងនូវបញ្ជីទាំងនេះតាមការតម្រូវដូចមាននៅក្នុងដីកាបង្គាប់ឲ្យដាក់ឯកសារ សម្រាប់ការត្រៀមរៀបចំសម្រាប់សវនាការជំនុំជម្រះក្ដី របស់អង្គជំនុំជម្រះនេះឡើយ។* (សង្កត់ន័យបន្ថែមដោយអក្សរទ្រេត) ប្រសិនបើ ការិយាល័យសហព្រះរាជអាជ្ញាទទួលបានការ អនុញ្ញាតឲ្យ ស្នើសុំសាក្សីបន្ថែមនៅក្នុងទូទាំងពេលនៃសវនាការជំនុំជម្រះក្ដីដូចអ្វីដែល កសព បានស្នើសុំនោះ មេធាវីការពារក្ដី យល់ឃើញថា ខណៈពេលដែលសវនាការចេះតែដំណើរការទៅមុខ ខ្លួនក៏ត្រូវតែទទួលបាននូវឱកាសស្មើៗគ្នាដើម្បីកោះហៅសាក្សីណាម្នាក់តាមដែលខ្លួនយល់ឃើញថាជាការចាំបាច់ចំពោះមេធាវីការពាររបស់លោក អៀង សារី នៅពេលដែលសវនាការជំនុំជម្រះក្ដី។ បើសិនជាមានការចាំបាច់ត្រូវឲ្យធ្វើការកោះហៅសាក្សីណាមួយចំនួន ក្នុងអំឡុងពេលនៃសវនាការ នោះមេធាវីការពារក្ដី នឹងស្វែងរកសុំការអនុញ្ញាតធ្វើដូចនេះហើយមេធាវីការពារក្ដីនឹងផ្ដល់ហេតុផលចាំបាច់ថាតើហេតុអ្វីបានជាដើម្បីជាផលប្រយោជន៍យុត្តិធម៌ត្រូវស្ដាប់ចម្លើយសាក្សី(ម្នាក់ ឬច្រើននាក់)?[8] ។

---

[7] ឯកសារលេខ E9/4/2, "បញ្ជីស្នើឈ្មោះអ្នកជំនាញរបស់ អៀង សារី និងសេចក្ដីជូនដំណឹងរបស់ អៀង សារី ទាក់ទងនឹងបញ្ជីឈ្មោះសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់", ១៤ កុម្ភៈ ២០១១, ERN 00644216-17 ។

[8] បញ្ជីឈ្មោះសាក្សីរបស់មេធាវីការពារក្ដី ត្រង់កថាខណ្ឌទី១ ។

៤. កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១, នួន ជា[9] និងអៀង ធីរិទ្ធ[10] បានដាក់នូវបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញដែលបានស្នើសុំរបស់ខ្លួន។ នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងដល់ ខៀវ សំផន ថា ការពន្យាពេលអាចនឹងអនុញ្ញាតឲ្យបានដើម្បីដាក់បញ្ជីឈ្មោះរបស់ខ្លួនដោយផ្អែកលើមូលដ្ឋាននៃបញ្ហាការបកប្រែរហូតទល់នឹងថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ ២០១១[11]។ កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១ ខៀវ សំផន[12] បានដាក់នូវបញ្ជីឈ្មោះសាក្សី និង អ្នកជំនាញដែលបានស្នើសុំរបស់ខ្លួន។ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ សហព្រះរាជអាជ្ញា[13], អៀង សារី[14], នួន ជា[15], និង ខៀវ សំផន[16], ទាំងអស់គ្នាបានដាក់នូវសេចក្តីសង្ខេបសាក្សីរបស់ខ្លួន អនុលោមតាមវិធាន៨០ នៃវិធានផ្ទៃក្នុង ។

## ៣. ច្បាប់ដែលពាក់ព័ន្ធ

៥. វិធាន៨០.២ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (“វិធាន”) នៅពេលដែលជនជាប់ចោទមានបំណងចង់ឲ្យកោះហៅសាក្សីណាម្នាក់....ត្រូវដាក់ជូនបញ្ជីឈ្មោះបន្ថែម... ក្នុងរយៈពេលដប់ប្រាំថ្ងៃគិតចាប់ពី

---

[9] ឯកសារលេខ E9/4/4, “បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើសុំ ”, ចុះថ្ងៃទី១៥ កុម្ភៈ ២០១១, ERN 00644407-16 ។

[10] ឯកសារលេខ E9/4/5, “បញ្ជីឈ្មោះអ្នកជំនាញដែលបានស្នើសុំរបស់ អៀង ធីរិទ្ធ” , ចុះថ្ងៃទី១៥ កុម្ភៈ ២០១១, ERN 0064447-53 ។

[11] ឯកសារលេខ E9/6/1, “សេចក្តីជូនដំណឹងស្តីពី ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំពន្យាពេលកំណត់ (E9/6) ” របស់អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៤ កុម្ភៈ ២០១១(ដែលត្រូវបានជូនដំណឹងពីថ្ងៃទី១៦ កុម្ភៈ ២០១១), ERN 00644101។

[12] ឯកសារលេខ E9/4/6, “បញ្ជីឈ្មោះសាក្សី និង អ្នកជំនាញ ដែលបានស្នើសុំ ”, ចុះថ្ងៃទី២១ កុម្ភៈ ២០១១, ERN 00646238-42។

[13] ឯកសារលេខ E9/13, “សេចក្តីសង្ខេបសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញរបស់ សហព្រះរាជអាជ្ញា”, ចុះថ្ងៃទី២៣ កុម្ភៈ ២០១១, ERN 00646780-84 ។

[14] ឯកសារលេខ E9/12, “សេចក្តីសង្ខេបអំពីមុខជំនាញ និងគុណវុឌ្ឍិរបស់អ្នកជំនាញនីមួយៗដែលបានស្នើសុំ និងចំណុចនានានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលអ្នកជំនាញនីមួយៗត្រូវបានរំពឹងទុកថានឹងត្រូវផ្តល់សក្ខីកម្ម អនុលោមតាមវិធាន៨០ របស់ អៀង សារី” , ចុះថ្ងៃទី២៣ កុម្ភៈ ២០១១, ERN 00646776-77 ។

[15] ឯកសារលេខ E9/10, “សេចក្តីសង្ខេបរបស់សាក្សី អ្នកជំនាញ និង ដើមបណ្តឹងរដ្ឋប្បវេណី ”, ចុះថ្ងៃទី២៣ កុម្ភៈ ២០១១, ERN 00646439-43 ។

[16] ឯកសារលេខ E9/11, “ការបញ្ជាក់លើសាក្សី និងអ្នកជំនាញដែលបានស្នើសុំ ”, ចុះថ្ងៃទី២៣ កុម្ភៈ ២០១១, ERN 00646535-38 ។

ថ្ងៃទទួលដំណឹងអំពីបញ្ជីឈ្មោះសាក្សីរបស់សហព្រះរាជអាជ្ញា។ វិធាន៣៩ នៃវិធានផ្ទៃក្នុង ចែងថា *"គ្រប់ពេលវេលាកំណត់ទាំងអស់ដែលមានចែងនៅក្នុងច្បាប់ជាធរមានវិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងសេចក្តីសម្រេចរបស់ចៅក្រមតាមករណីសមស្របណាមួយត្រូវតែគោរព។ ក្នុងករណីនេះការមិនគោរពតាមកាលកំណត់ គឺនាំឱ្យកិច្ចដែលបានធ្វើនោះត្រូវចាត់ទុកជាអសុពលភាព"* ។ វិធាន៣៩.៤ អនុញ្ញាតឱ្យអង្គជំនុំជម្រះ ពន្យាពេលវេលាកំណត់ដូចដែលខ្លួនបានកំណត់...បើសិនជាខ្លួនយល់ឃើញថាត្រឹមត្រូវសមហេតុសមផល ។

៦. មាត្រា៩ នៃសេចក្តីណែនាំអនុវត្តចែងថាឯកសារអាចត្រូវបានដាក់ក្រៅពីពេលវេលាកំណត់ដូចដែលមានចែងនៅក្នុងវិធាន៣៩ នៃវិធានផ្ទៃក្នុងបាន ប៉ុន្តែក្នុងករណីនេះអ្នកដែលដាក់ឯកសារ *ត្រូវបញ្ជាក់ពីមូលហេតុនៃការនាំឱ្យមានការពន្យាពេល* ហួសពីការកំណត់នៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឯកសារ ។ វិធានអនុញ្ញាតឱ្យចៅក្រម ឬ អង្គជំនុំជម្រះ ដែលត្រូវដាក់ឯកសារជូន ទទួលយក ឬច្រានចោលឯកសារនោះទោះបីជាមានការយឺតយ៉ាវក្នុងការដាក់ក្តី ។

៧. បទប្បញ្ញត្តិរៀបចំសវនាការចែងក្នុងវិធាន៨០ ត្រូវបានចម្លងយកមកពីបទប្បញ្ញត្តិរៀបចំសវនាការនៅតុលាការអន្តរជាតិស្រដៀងគ្នា ដោយមានការកាត់សេចក្តីលើការរំលោភសិទ្ធិមនុស្សដែលមានទំហំស្រដៀងគ្នា។ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY") បទប្បញ្ញត្តិស្រដៀងគ្នានេះ ត្រូវបានរកឃើញនៅក្នុង វិធាន៦៥ ស្ទួនលើកទីបី (Rule 65 *ter*) នៃវិធានស្តីពីភស្តុតាង និងនីតិវិធីរបស់ខ្លួន[17] ។ សំណួរអំពីថាតើបញ្ជីឈ្មោះសាក្សីរបស់ភាគីនានាអាចត្រូវបានបន្ថែម ឬកែប្រែដែរឬទេ នៅក្រោយកាលបរិច្ឆេទកំណត់ដែលបានដាក់ដោយអង្គជំនុំជម្រះសាលាដំបូង ត្រូវបានពិចារណាដោយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY នៅក្នុង

---

[17] តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY"), វិធានស្តីពីភស្តុតាង និងនីតិវិធី, IT/32/Rev.45, ថ្ងៃទី៨ ធ្នូ ២០១០ ។

ករណីរបស់ *Milan Lukic*[18] ។ នៅក្នុងករណីនេះ អង្គជំនុំជម្រះបានសម្រេចថា វាគឺជាយុត្តិសាស្ត្រដែលបានដោះស្រាយរួចហើយដែលថា បញ្ជីឈ្មោះសាក្សីអាចត្រូវបានកែប្រែបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា បើធ្វើដូច្នោះវាស្ថិតនៅក្នុងផលប្រយោជន៍នៃយុត្តិធម៌[19] ។ នៅក្នុងការកំណត់ថាតើវាជាផលប្រយោជន៍នៃយុត្តិធម៌ដែរឬទេ ក្នុងការអនុញ្ញាតឱ្យភាគីនានាធ្វើការកែប្រែបញ្ជីឈ្មោះរបស់ខ្លួន (នៅក្នុងករណីនោះ រដ្ឋអាជ្ញា) អង្គជំនុំជម្រះសាលាដំបូង បានសម្រេចពិចារណាលើកត្តានានាដូចតទៅនេះ៖

"រួមមាន តើភាគីដើមបណ្ដឹងបានបង្ហាញពីបុព្វហេតុល្អក្នុងសំណើរបស់ខ្លួនដែរឬទេ, ដំណាក់កាលនៃដំណើរការនីតិវិធីដែលសំណើនោះត្រូវបានធ្វើឡើង, ថាតើការអនុញ្ញាតឱ្យមានការកែប្រែ នឹងនាំបណ្ដាលឱ្យការពន្យារពេលដំណើរការនីតិវិធីមិនត្រឹមត្រូវ និងធ្វើឱ្យសក្ខីកម្មមានលក្ខណៈដដែលៗ និងលក្ខណៈត្រួត។ អង្គជំនុំជម្រះសាលាដំបូង អាចនឹងពិចារណាផងដែរពីភាពស្មុគស្មាញនៃករណីរឿង, កិច្ចស៊ើបសួរដែលកំពុងបន្ត, និងការបកប្រែឯកសារ និងសម្ភារៈផ្សេងៗ ។ (កំណត់សម្គាល់ជើងទំព័រត្រូវបានដកចេញ)។ អង្គជំនុំជម្រះសាលាដំបូងនេះក៏មានទស្សនៈផងដែរថាវាពាក់ព័ន្ធទៅនឹងការពិចារណាថាតើ ភាគីដើមបណ្ដឹងបានធ្វើការព្យាយាមដ៏ហ្មត់ចត់ (due diligence) នៅពេលឆាប់បំផុតតាមដែលអាចធ្វើទៅបានដែរឬទេ នៅក្នុងការកំណត់អត្តសញ្ញាណសាក្សីដែលបានស្នើសុំ"[20] ។

៨. នៅក្នុងបរិបទនៃកាតព្វកិច្ចរបស់ភាគីក្នុងការដាក់បញ្ជីឈ្មោះសាក្សី និងឯកសាររបស់ខ្លួនសម្រាប់សវនាការដូចដែលបានចែងនៅក្នុង វិធាន៦៥ ស្ទួនលើកទីបី (Rule 65 *ter*) នៃតុលាការ ICTY

---

[18] *រដ្ឋអាជ្ញា ទល់នឹង Milan Lukic and Sredoje Lukic*, សេចក្ដីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញាស្នើសុំឱ្យកែប្រែបញ្ជីឈ្មោះសាក្សី និងសារណានានាដែលពាក់ព័ន្ធ តាមវិធាន៦៥ ស្ទួនលើកទីបី (Rule 65 *ter*), IT-98-3211-PT, ថ្ងៃទី២២ មេសា ២០០៨ ត្រង់កថាខណ្ឌទី ៩ ។

[19] *រដ្ឋអាជ្ញា ទល់នឹង Milan Lukic and Sredoje Lukic*, កថាខណ្ឌទី ៩ ។

[20] *រដ្ឋអាជ្ញា ទល់នឹង Milan Lukic and Sredoje Lukic*, កថាខណ្ឌទី ១០ ។

អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ពីសារៈសំខាន់របស់ភាគីនានាក្នុងការធ្វើឲ្យត្រូវតាម កាលបរិច្ឆេទកំណត់ និងភាពចាំបាច់នៃការដាក់ទណ្ឌកម្មបើភាគីទាំងនោះធ្វើមិនត្រូវតាមកាលបរិច្ឆេទកំណត់ ។ អង្គជំនុំជម្រះនោះ បានសម្រេចថា៖

"ខណៈដែលវាជាគោលការណ៍សម្រាប់ភាគីនីមួយៗក្នុងការសម្រេចថា តើសាក្សីណាមួយត្រូវកោះហៅឲ្យមកបង្ហាញសក្ខីកម្មលើករណីរឿងរបស់ខ្លួន ភាគីទាំងនោះគឺឋិតនៅក្រោមកាតព្វកិច្ចទូទៅមួយដែលធ្វើឲ្យត្រូវតាមកាលបរិច្ឆេទដែលបានកំណត់ និងត្រូវធ្វើការព្យាយាមដ៏ហ្មត់ចត់ (due diligence) នៅក្នុងការត្រៀមរៀបចំរបស់ខ្លួន ។ អនុលោមតាមវិធាន៦៥ ស្ទួនលើកទីបី (Rule 65 *ter*) អង្គជំនុំជម្រះសាលាដំបូង បានកត់សម្គាល់ និងបានសម្រេចថា នីតិវិធីដែលមានចែងនៅក្នុងនេះត្រូវបានចងក្រងប្រមូលផ្តុំ នោះវាអាចនឹងដាក់ទណ្ឌកម្មភាគីទាំងឡាយណាដែលមិនបានធ្វើតាមកាតព្វកិច្ចរបស់ខ្លួនដោយអនុលោមតាមវិធាន៦៥ ស្ទួនលើកទីបី (Rule 65 *ter*)"[21] ។

៩. វិធាន៦៥ ស្ទួនលើកទីបី (Rule 65 *ter*) នៃតុលាការ ICTY បានចែងថា៖

"ក្នុងករណីរឿងនេះមានកើតឡើង អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចលើការដាក់ទណ្ឌកម្មភាគីណាដែលខកខានមិនអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួន ដោយអនុលោមតាមវិធានបច្ចុប្បន្ននេះ ។ ទណ្ឌកម្មបែបដូច្នោះ អាចមានទាំង ការមិនដាក់បញ្ចូលនូវភស្តុតាងជាឯកសារ និង ជាវត្ថុតាងផងដែរ" ។

## ៤. អំណះអំណាង

[21] *រដ្ឋអាជ្ញា ទល់នឹង Milan Lukic and Sredoje Lukic*, កថាខណ្ឌទី ១៥ ។

00657373



១០. ដូចជាបញ្ហាដំបូងដែលញត្តិនេះស្នើសុំឲ្យសាក្សីនានាដែលត្រូវកោះហៅត្រូវបានដាក់ ២៩ថ្ងៃ ក្រោយពេលដែលកាលបរិច្ឆេទកំណត់ដែលបង្គាប់ដោយអង្គជំនុំជម្រះសាលាដំបូង - ដោយគ្មានការបញ្ជាក់ណាមួយពីមូលហេតុពន្យារទេ (យ៉ាងហោចណាស់ក៏នៅក្នុងតួសេចក្តីនៃញត្តិដែរ) - វាគួរតែត្រូវបានបដិសេធចោល ។ វិធាន ៣៩ និងមាត្រា ៩ នៃសេចក្តីណែនាំអនុវត្ត តម្រូវឲ្យមានបែបដូច្នោះ ហើយជាផលវិបាក អនុញ្ញាតឲ្យច្រានចោលនូវការដាក់ឯកសារនានាដែលបំពានលើបទប្បញ្ញត្តិទាំងនេះ ។ បើភាគីនានាខកខានមិនបានធ្វើឲ្យត្រូវតាមកាលបរិច្ឆេទដែលកំណត់ដោយអង្គជំនុំជម្រះ លើកលែងតែមូលហេតុល្អត្រូវបានបង្ហាញពីលទ្ធភាពនៃអង្គជំនុំជម្រះសាលាដំបូង ក្នុងការគ្រប់គ្រងលើសវនាការនេះដើម្បីធានាថាវាជាការត្រឹមត្រូវ និងឆាប់រហ័ស ត្រូវបានកាត់បន្ថយយ៉ាងច្រើន ។ ភាគីនានាមានកាតព្វកិច្ចធ្វើឲ្យត្រូវតាមដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ហើយបើពួកគេមិនអាចទេនោះ ពួកគេត្រូវប្រាប់ថាមកពីមូលហេតុអ្វី ។

១១. ជាខ្លឹមសារនៃសំណើដែលបានប្រើពិសោធន៍ដែលបានផ្តល់នៅក្នុងករណីរបស់ *Milan Lukic*[22] មេធាវីការពារក្តីមិនបានបង្ហាញពីមូលហេតុល្អដែលវាស្ថិតនៅក្នុងផលប្រយោជន៍នៃយុត្តិធម៌ទេ ក្នុងការកោះហៅសាក្សីទាំងនេះ ក្រោយពីបានថ្លែងនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ថា "មិនមានចេតនាកោះហៅសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីណាមួយនៅពេលនេះទេ ហើយដូច្នេះនឹងមិនមានការផ្តល់ជូនដល់អង្គជំនុំជម្រះសាលាដំបូង នូវបញ្ជីឈ្មោះទាំងនេះដូចដែលបានតម្រូវនៅក្នុងដីកាបង្គាប់ឲ្យដាក់សម្ភារៈសម្រាប់រៀបចំសវនាការទេ"[23] ។

១២. ទីមួយ ញត្តិនេះមិនត្រូវទៅតាមលក្ខខណ្ឌតម្រូវរបស់អង្គជំនុំជម្រះសាលាដំបូង ដូចដែលបានដាក់ជាគោលនៅក្នុងដីកាបង្គាប់រៀបចំសវនាការទេ ។ អង្គជំនុំជម្រះសាលាដំបូង បានតម្រូវឲ្យភាគី

[22] *រដ្ឋអាជ្ញា ទល់នឹង Milan Lukic and Sredoje Lukic* ។

[23] បញ្ជីឈ្មោះអ្នកជំនាញរបស់មេធាវីការពារក្តី ត្រង់កថាខណ្ឌទី ១ ។

នានាដាក់ជូននូវពត៌មានចំនួន ៨បែប ផ្សេងៗគ្នាសម្រាប់សាក្សីនីមួយៗក្នុងគោលបំណងដើម្បីជួយដល់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងការកំណត់រកថា តើសាក្សីណាមួយគួរត្រូវបានកោះហៅឱ្យចូលសវនាការ[24] ។ សំខាន់ជាងនេះទៀត សាក្សីនានាដែលបានកំណត់អត្តសញ្ញាណរួចហើយមិនត្រូវបានអមទៅដោយសេចក្តីសង្ខេបអង្គហេតុ និងចំណុចនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូចដែលបានតម្រូវឱ្យមានដែលសាក្សីដែលបានស្នើនីមួយៗនោះត្រូវបានគេរំពឹងថានឹងផ្តល់សក្ខីកម្ម នោះឡើយ[25] ។ ភាគីនីមួយ ត្រូវបានបង្គាប់ឱ្យដាក់បញ្ជីឈ្មោះសាក្សី និងសេចក្តីសង្ខេបសាក្សីនានារបស់ខ្លួននៅក្នុងទម្រង់មួយដ៏ត្រឹមត្រូវ ។ ដីកាបង្គាប់មិនអនុញ្ញាតឱ្យសាក្សីដែលបានស្នើសុំរបស់ភាគីមួយ ទៅភាគីមួយទៀតនោះឡើយ ។ ការធ្វើដូច្នេះ វានឹងគេចវាងពីគោលបំណងនៃការអនុវត្តនេះក្នុងការយល់ដឹងពីជនជាប់ចោទនីមួយៗថាតើហេតុអ្វីបានជាបុគ្គលទាំងនេះត្រូវបានកោះហៅយ៉ាងជាក់លាក់ ហើយថាតើព័ត៌មានជាក់លាក់អ្វីខ្លះដែលគេរំពឹងថាពួកគាត់ត្រូវផ្តល់ ហើយនិង លើសពីនេះទៀត ថាតើភាពទាក់ទងអ្វីខ្លះដែលពួកគាត់មាននៅក្នុងការបង្ហាញសក្ខីកម្ម ឬមួយបដិសេធអង្គហេតុសំខាន់ៗ ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។

១៣. ទីពីរ ញត្តិនេះមានភាពស្រពេចស្រពិល ដោយហេតុថាវាខកខានមិនបានកំណត់ឱ្យបានច្បាស់លាស់ពីបញ្ជីឈ្មោះសាក្សីពេញលេញដែលមេធាវីការពារក្តីស្វែងរកដើម្បីស្នើសម្រាប់សវនាការ ។ មេធាវីការពារក្តីអះអាងថា ខ្លួនគាំទ្រចំពោះសំណើរបស់ នួន ជា និង ខៀវ សំផន ឱ្យកោះហៅ "អតីតសមាជិកនៃការិយាល័យសហចៅក្រមស៊ើបអង្កេត *ដូចជា* ចៅក្រម យូ ប៊ុនឡេង និង Marcel Lemonde និង លោក Wayne Bastin" [សង្កត់ន័យត្រង់អក្សរទ្រេត][26] ។ ផ្នែកនៃសំណើនេះមានភាពខ្វះខាតអំពីការកំណត់ចំនួនសាក្សីដែលខ្លួនមានបំណងឱ្យកោះហៅ។ គេមិនគួររំពឹងទុកទៅលើអង្គជំនុំជម្រះសាលាដំបូង ថាជាអ្នកត្រូវសម្លឹងមើលពីចេតនាពិតប្រាកដថាតើចំនួនសាក្សីប៉ុន្មាន

[24] ដីកាបង្គាប់រៀបចំសវនាការ, កថាខណ្ឌទី ២ ។

[25] ដីកាបង្គាប់រៀបចំសវនាការ, កថាខណ្ឌទី ៦ ។

[26] ញត្តិ, កថាខ័ណ្ឌទី១ ។

00657375



នាក់ដែលមេធាវីការពារក្ដីនេះចង់ស្វែងរកដើម្បីមកបំភ្លឺនៅពេលសវនាការឡើយ។ មេធាវីការពារក្ដីត្រូវតែពន្យល់ឱ្យបានជាក់លាក់ថា តើសាក្សីណាដែលខ្លួនស្វែងរកដើម្បីកោះហៅ ដើម្បីអនុញ្ញាតឱ្យភាគីដទៃអាចត្រៀមរៀបចំករណីរបស់គេ ។

១៤. ទីបី មេធាវីការពារក្ដីខកខានមិនបានបង្ហាញឱ្យឃើញថា ខ្លួនបានអនុវត្តយ៉ាងប្រុងប្រយ័ត្នក្នុងការធ្វើអត្តសញ្ញាណកម្មសាក្សីដែលស្នើឡើងទាំងនេះតាំងពីពេលដំបូងបង្អស់មកម្ល៉េះ ។ ក្រុមសាក្សីតូចមួយនេះ យ៉ាងហោចណាស់ក្រុមសាក្សីដែលបានកំណត់អត្តសញ្ញាណបានយ៉ាងគ្រប់គ្រាន់នៅក្នុងញត្តិនេះ បានជាកម្មវត្ថុនៃវិវាទដ៏ទូលំទូលាយដោយមេធាវីការពារក្ដី - នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំនៅទូទាំងកិច្ចដំណើរការនេះ ដូចមានភស្ដុតាងបង្ហាញស្រាប់តាមរយៈសេចក្ដីយោងនៅក្នុងញត្តិនេះ ។ មេធាវីការពារក្ដីត្រូវតែបានយល់ដឹងអំពីសាក្សីទាំងនេះនៅពេលធ្វើការសម្រេចចិត្តដើម្បីជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង ដែលខ្លួនបានស្នើមិនឱ្យកោះហៅសាក្សីណាម្នាក់នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ។

១៥. ដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង មិនអនុញ្ញាតឱ្យមេធាវីការពារក្ដីធ្វើការសម្រេចចិត្តនៅពេលផ្ដល់ព័ត៌មានដល់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងសាក្សីដែលខ្លួនស្វែងរកឱ្យកោះហៅនោះទេ ដោយហេតុថាការណ៍នេះជាការទទួលខុសត្រូវរបស់ខ្លួនដើម្បីគ្រប់គ្រងសវនាការតាមដែលខ្លួនយល់ថាសមស្រប ជាប្រយោជន៍ក្នុងការកំណត់អំពីការពិត ។ ហេតុដូច្នេះ ដោយសារអវត្តមាននៃការពន្យល់ណាមួយអំពីថា តើហេតុអ្វីបានជាមេធាវីការពារក្ដីបានជ្រើសរើស ១) មិនផ្ដល់ព័តមានទៅឱ្យអង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងចេតនារបស់ពួកគេក្នុងការកោះហៅសាក្សី ឬ ២) ថាហេតុអ្វីបានជាសាក្សីទាំងនេះមិនអាចឱ្យគេកំណត់អត្តសញ្ញាណបាន បើមានការអនុវត្តដោយប្រុងប្រយ័ត្ននោះ នៅពេលមេធាវីការពារក្ដីបានដាក់ការជូនដំណឹងរបស់ខ្លួនមិនឱ្យកោះហៅសាក្សី

នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ - ពួកគេមិនគួរត្រូវបានអនុញ្ញាតឱ្យបន្ថែមសាក្សីទៅក្នុងបញ្ជីឈ្មោះអ្នកជំនាញរបស់ពួកគេទៀតឡើយ ។

## ៥. ដំណោះស្រាយដែលស្នើសុំ

១៦. ជាការសន្និដ្ឋាន មេធាវីការពារក្តី (១) ខកខានមិនបានផ្តល់មូលហេតុអំពីការដាក់ឯកសារយឺត (២) ខកខានមិនបានផ្តល់សាក្សីពាក់ព័ន្ធ និងសេចក្តីកម្មលំអិតដូចបានតម្រូវដោយអង្គជំនុំជម្រះសាលាដំបូង (៣) ខកខានមិនបានកំណត់អត្តសញ្ញាណពីចំនួនសាក្សីពិតប្រាកដដែលខ្លួនចង់ស្នើសុំឱ្យកោះហៅ (៤) ខកខានមិនបានផ្តល់មូលហេតុអំពីតើហេតុអ្វីបានជាសាក្សីដែលខ្លួនបានកំណត់អត្តសញ្ញាណរួចហើយនោះ មិនត្រូវបានដាក់បញ្ចូលក្នុងបញ្ជីឈ្មោះសាក្សី តាមកាលបរិច្ឆេទកំណត់កាលពី២៩ថ្ងៃកន្លងទៅនេះ ដែលជាផ្នែកនៃភារកិច្ចរបស់ពួកគេដែលត្រូវតែធ្វើសកម្មភាពដោយប្រុងប្រយ័ត្ន ។ តាមមូលហេតុដូចខាងលើ សហព្រះរាជអាជ្ញាស្នើឱ្យបដិសេធចោលញត្តិនេះ ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ | **លោក យ៉េត ចរិយា**<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | [signature] |
| | **លោក** William Smith<br>សហព្រះរាជអាជ្ញារង | | [signature] |